**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

<u>សេចក្ដីប្រកាសព័ត៌មាន</u>

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានបញ្ចប់ទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា បានបញ្ចប់ទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រកបដោយលទ្ធផលផ្លែផ្កា ពីថ្ងៃទី៦ ដល់ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៥។ នៅក្នុងឱកាសបំពេញទស្សនកិច្ចនេះ សម្ដេច បានជួបពិភាក្សាការងារទ្វេភាគីជាមួយ ឯកឧត្តមបណ្ឌិត សាយសំផន គុមវិហាន ប្រធានរដ្ឋសភាឡាវ និង ឯកឧត្តមបណ្ឌិត សនសៃ ស៊ីផាន់ដន នាយករដ្ឋមន្ត្រីឡាវ។

នៅក្នុងជំនួបទាំងពីរខាងលើ ថ្នាក់ដឹកនាំឡាវបានសម្ដែងនូវអំណរគុណចំពោះកម្ពុជា ដែលបានគាំទ្រ និងផ្ដល់ជំនួយ ព្រមទាំងរួមចំណែកដល់ភាពជោគជ័យរបស់ឡាវក្នុងការធ្វើជាប្រធានអាស៊ាន និងការរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៥ កិច្ចប្រជុំកំពូល ACMECS លើកទី១០ និងព្រឹត្តិការណ៍ពាក់ព័ន្ធ នៅឆ្នាំ២០២៤។ សម្ដេចតេជោក៏បានថ្លែងអំណរគុណមិត្តឡាវ ដែលបានបញ្ជូន គណៈប្រតិភូជាន់ខ្ពស់ចូលរួមមហាសន្និបាតសន្និសីទអន្តរជាតិនៃបណ្ដាគណបក្សនយោបាយនៅអាស៊ីលើកទី១២ នៅកម្ពុជា សម័យប្រជុំពេញអង្គនៃសភាអន្តរជាតិដើម្បីភាពអត់ឱននិងសន្តិភាពលើកទី១១ និងកិច្ចប្រជុំកំពូលសៀមរាប-អង្គរស្ដីពីពិភពលោកមួយដែលគ្មានមីន ដែលទាំងនេះសបញ្ជាក់អំពីចំណងមិត្តភាព និងសាមគ្គីភាពជាប្រពៃណីដ៏ជ្រាលជ្រៅនៃប្រទេសទាំងពីរ។

ថ្នាក់ដឹកនាំកម្ពុជា និងឡាវ បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងជាប្រពៃណី និងយូរអង្វែងរវាងប្រទេសទាំងពីរ ដែលបានបន្តរីកចម្រើនឥតឈប់ឈរលើគ្រប់វិស័យ ស្របតាមស្មារតី "**ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែង**" ដែលភាគីទាំងពីរបានបង្កើតឡើងនៅឆ្នាំ២០១៩ និងផែនទីបង្ហាញផ្លូវសម្រាប់បន្តកិច្ចសហប្រតិបត្តិការទ្វេភាគី ជាពិសេសសម្រាប់អ្នកដឹកនាំបន្តវេន ក្នុងការបន្តពូនជ្រំ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការបន្ថែមទៀត។ ភាគីទាំងពីរបានសម្ដែងនូវការពេញចិត្តចំពោះការប្រាស្រ័យទាក់ទងគ្នាជាបងប្អូន និងការផ្លាស់ប្ដូរទស្សនកិច្ចជាញឹកញាប់រវាងថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់ ទាំងក្នុងក្របខ័ណ្ឌនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងគណបក្ស ដែលបានបង្កើននូវជំនឿជឿជាក់ដ៏រឹងមាំ និងធ្វើឱ្យទំនាក់ទំនងកម្ពុជា-ឡាវកាន់តែជិតស្និទ្ធ និងស៊ីជម្រៅបន្ថែមទៀត។ ថ្នាក់ដឹកនាំទាំងពីរបានអបអរសាទរចំពោះលទ្ធផលដ៏ជោគជ័យ និងត្រចះត្រចង់នៃទស្សនកិច្ចផ្លូវការរបស់ឯកឧត្តមបណ្ឌិត សនសៃ ស៊ីផាន់ដន នាយករដ្ឋមន្ត្រីឡាវ នៅកម្ពុជា កាលពីខែធ្នូ ឆ្នាំ២០២៤ និងបានចាត់ទុកទស្សនកិច្ចផ្លូវការរបស់សម្ដេចតេជោ ហ៊ុន សែន នាពេលនេះ ជាទស្សនកិច្ចលើកដំបូងក្នុងនាម

ជាប្រធានព្រឹទ្ធសភា ដែលកាន់តែពង្រឹងនិងពង្រីកភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែង សម្រាប់ជាគុណប្រយោជន៍ដ៏ធំធេងជូនជាតិមាតុភូមិ និងប្រជាជន នៃប្រទេសទាំងពីរ ទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។

ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរក៏បានប្តេជ្ញាបន្តពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការដែលមានស្រាប់ ជាពិសេសការជំរុញវិស័យពាណិជ្ជកម្មនិងវិនិយោគ, វិស័យថាមពលនិងអគ្គិសនី, អប់រំ, ទេសចរណ៍, ការផ្លាស់ប្តូរប្រជាជននិងប្រជាជន, សន្តិសុខនិងការពារជាតិ, និងការពន្លឿនការកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ព្រមទាំងការអនុវត្តកិច្ចព្រមព្រៀងនិងអនុស្សរណៈយោគយល់គ្នានៃប្រទេសទាំងពីរឱ្យកាន់តែមានប្រសិទ្ធភាព។ ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរក៏បានពិភាក្សានិងផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងអន្តរជាតិ ដែលកំពុងប្រែប្រួល ពិបាកប៉ាន់ស្មាន និងជាកង្វល់រួម ព្រមទាំងបានឯកភាពបន្តសហការ និងគាំទ្រគ្នាទៅវិញទៅមក ក្នុងក្របខ័ណ្ឌអនុតំបន់ និងពិភពលោក។

**សម្តេចតេជោ** ក៏បានពាំនាំការអញ្ជើញរបស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា ជូន ឯកឧត្តមបណ្ឌិត **សាយសំផន គុមវិហាន** មកបំពេញទស្សនកិច្ចនៅកម្ពុជា នាវេលាសមស្រប។ ឯកឧត្តមបណ្ឌិត បានទទួលយកការអញ្ជើញនេះដោយក្តីរីករាយ។

ក្នុងអំឡុងពេលទស្សនកិច្ចនេះដែរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានធ្វើជាសហប្រធានជាមួយ ឯកឧត្តម **ថងលុន ស៊ីសុលីត** ប្រធានរដ្ឋឡាវ និងជាអគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ ក្នុងកិច្ចប្រជុំកំពូលលើកទី១៥ រវាងគណបក្សប្រជាជនកម្ពុជា និងបក្សប្រជាជនបដិវត្តន៍ឡាវ។ ថ្នាក់ដឹកនាំទាំងពីរបានវាយតម្លៃខ្ពស់ចំពោះការផ្លាស់ប្តូរទស្សនកិច្ច និងជំនួបរវាងថ្នាក់ដឹកនាំជាន់ខ្ពស់បក្សនិងរដ្ឋនៃប្រទេសទាំងពីរនាឆ្នាំកន្លងទៅ ដែលបានពង្រឹងជំនឿទុកចិត្តគ្នាកាន់តែរឹងមាំ និងបន្តកិច្ចសហប្រតិបត្តិការ និងមិត្តភាពកាន់តែស្អិតរមួតរវាងថ្នាក់ដឹកនាំគណបក្ស និងប្រទេសទាំងពីរ ស្របតាមស្មារតីនៃកិច្ចប្រជុំកំពូលលើកទី១៤ នាខែមេសា ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ។ ជាមួយគ្នានេះ **សម្តេចតេជោ** បានជំរុញឱ្យមានជំនួបជាទៀងទាត់រវាងថ្នាក់ដឹកនាំគណបក្ស និងស្ថាប័នពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ទាំងអស់។ បន្ទាប់ពីកិច្ចប្រជុំនេះ ក៏មានការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការរវាងគណៈទាក់ទងបរទេសនៃគណបក្សទាំងពីរ និងរវាងយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងសហភាពយុវជនបក្សប្រជាជនបដិវត្តន៍ឡាវ។

ទស្សនកិច្ចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជា នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នាពេលនេះ ពិតជាមានសារៈសំខាន់ ជាពិសេសក្នុងបរិបទដែលពិភពលោកកំពុងប្រែប្រួល និងពិបាកប៉ាន់ស្មាន ដោយបានផ្តល់នូវសន្ទុះ និងថាមពលថ្មីសម្រាប់ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនិងយូរអង្វែងរវាងកម្ពុជា និងឡាវឱ្យកាន់តែរឹងមាំ ស៊ីជម្រៅ និងប្រកបដោយផ្លែផ្កាបន្ថែមទៀត។

ថ្ងៃសុក្រ ១០កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៥